# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុស្តីពីកិច្ចប្រជុំលើកទី១៣ របស់ក្រុមប្រឹក្សាយោបល់រេដបូក

ឆ្នាំពីរពាន់ដប់ប្រាំ ខែធ្នូ ថ្ងៃទី២៨ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ មានបើកកិច្ចប្រជុំលើកទី១៣ក្រុមប្រឹក្សាយោបល់រេដបូក ក្រោមការដឹកនាំសម្របសម្រួលរបស់សហប្រធាននៃអង្គប្រជុំ ដែលមានលោកបណ្ឌិត ឃនសារ៉េត ជាប្រធានលេខាធិការដ្ឋានក្រុមការងាររេដបូកកម្ពុជា និងលោកយាង ដូណាល់ ជាប្រធានក្រុមប្រឹក្សាយោបល់រេដបូក។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន២៦នាក់ រួមមាន ក្រុមប្រឹក្សាយោបល់រេដបូកកម្ពុជាដែលមានសមាជិកជាតំណាងសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ជលផល ជនជាតិដើមភាគតិច គ្រឹះស្ថានអប់រំ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអង្គការសង្គមស៊ីវិលមូលដ្ឋាន និងមន្ត្រីលេខាធិការដ្ឋានជាអ្នករៀបចំ និងគាំទ្រដំណើរការនៃកិច្ចប្រជុំ ដូចមានភ្ជាប់ជូនក្នុងឯកសារឧបសម្ព័ន្ធ៖ បញ្ជីវាយនាមអ្នកចូលរួម។

កិច្ចប្រជុំមានគោលបំណង បង្កើនការយល់ដឹងស្តីពីវឌ្ឍនភាពរេដបូកនៅកម្ពុជា បច្ចុប្បន្នភាពរេដបូកក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងរៀបចំផែនការសកម្មភាពឆ្នាំ២០១៦ សម្រាប់ក្រុមប្រឹក្សាយោបល់រេដបូក ដែលមានដំណើរការដូចមានភ្ជាប់ជូនក្នុងឯកសារឧបសម្ព័ន្ធ៖ របៀបវារៈកិច្ចប្រជុំ។

លោក យាង ដូណាល់ បានបង្ហាញលទ្ធផលការងារ និងបានបញ្ជាក់ថាបានសម្រេចតាមផែនការឆ្នាំ២០១៥។ លទ្ធផលទាំងនោះរួមមានៈ ការអនុម័តលើការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោបល់រេដបូកកម្ពុជា ការជ្រើសរើសប្រធាន និងសមាជិកក្រុមប្រឹក្សាយោបល់ដើម្បីជំនួសប្រធាន និងសមាជិកចាស់ដែលបានលាលែង ការបណ្តុះបណ្តាលរួមទាំងទស្សនកិច្ចសិក្សាដើម្បីពង្រឹងសមត្ថភាពក្រុមប្រឹក្សាយោបល់ស្តីពីការប្រែប្រួលអាកាសធាតុ និងទស្សនៈទានរេដបូក ការចូលរួមដំណើការពិគ្រោះយោបល់ស្តីពីសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ និងជាពិសេសបានផ្តល់អនុសាសន៍ជាលាយលក្ខណ៍អក្សរជូនលេខាធិការដ្ឋានក្រុមការងាររេដបូកកម្ពុជា ដើម្បីធានាថាការព្រួយបារម្មណ៍ និងផលប្រយោជន៍សហគមន៍ ត្រូវបានដោះស្រាយប្រកបដោយសមធ៌ម និងបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្ររេដបូកជាតិ ។

លោកបណ្ឌិត ឃន សារ៉េត បានបង្ហាញស្តីពីបច្ចុប្បន្នភាពក៏ដូចជាសេចក្តីសម្រេចនានារបស់សន្និសិទីអន្តរជាតិរដ្ឋនៃភាគីលើកទី២១នៅទីក្រុងប៉ារីស៍ និងវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ(NRS)។ ជាបន្ត លោក ញ៉ែម សុវណ្ណា បានបង្ហាញពីវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ(NFMS) ការរៀបចំប្រព័ន្ធព័ត៌មានធានាសុវត្ថិភាព(SIS) និងការរៀបចំកម្រិតបំភាយយោងពីព្រៃឈើ/កម្រិតយោងព្រៃឈើ (FREL/ FRL( ដូចមានភ្ជាប់ជូន ក្នុងឯកសារឧបសម្ព័ន្ធ៖ បទបង្ហាញស្តីពីCOP 21 និងការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ( NRS )។

ជាបន្តបន្ទាប់ សមាជិកក្រុមប្រឹក្សាយោបល់រេដបូក បានបង្ហាញពីលទ្ធផលការងារ និងការលំបាករបស់ក្រុមខ្លួនដែលបានអនុវត្តក្នុងឆ្នាំ២០១៥ ព្រមទាំងបានលើកឡើងនូវផែនការសកម្មភាពឆ្នាំ២០១៦ ដូចមានភ្ជាប់ជូនក្នុងឯកសារឧបសម្ព័ន្ធ៖ ផែនការសកម្មភាពឆ្នាំ២០១៦របស់សមាជិកនីមួយៗ។

ផ្អែកលើផែនការសកម្មភាពឆ្នាំ២០១៦របស់សមាជិកនីមួយៗ ក្រុមក៏បានពិភាក្សាដាក់បញ្ចូលនូវមតិយោបល់បង្កើតជាផែនការរួមរបស់ក្រុមប្រឹក្សាយោបល់ឆ្នាំ២០១៦ ដូចមានភ្ជាប់ជូនក្នុងឯកសារឧបសម្ព័ន្ធ៖ ផែនការសកម្មភាព ប្រចាំឆ្នាំ២០១៦ក្រុមប្រឹក្សាយោបល់រេដបូកកម្ពុជា។

បន្ថែមលើនេះ កិច្ចប្រជុំក៏បានធ្វើតារាងវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមប្រឹក្សាយោបល់ ដើម្បីសិក្សាពីលទ្ធភាពក្នុងការគាំទ្រចំណុចខ្វះខាតកន្លងមក ដូចមានភ្ជាប់ជូនក្នុងឯកសារឧបសម្ព័ន្ធ៖ តារាងវិភាគចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមប្រឹក្សាយោបល់។

តាមការពិភាក្សា និងការឯកភាព កិច្ចប្រជុំបានធ្វើសេចក្តីសម្រេចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ឯកសារស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាយោបល់រេដបូកកម្ពុជា គួរពិនិត្យកែសម្រួលខ្លឹមសារ និងពាក្យមួយចំនួនឲ្យបានសមស្រប
- លោក យាង ដូណាល់ នឹងបំពេញបន្ថែមលើផែនការសកម្មភាពប្រចាំឆ្នាំ២០១៦ក្រុមប្រឹក្សាយោបល់រេដបូកកម្ពុជាឲ្យមាន សូចនាករណ៍ ពេលវេលា និងថវិកា នឹងផ្ញើរជូន លោក ញ៉ែម សុវណ្ណា ដើម្បីពិនិត្យពីលទ្ធភាពថវិកាគាំទ្រ
- ឆ្នាំ២០១៦នេះ ក្រុមប្រឹក្សាយោបល់នឹងផ្តោតសំខាន់លើការផ្សព្វផ្សាយបន្តបង្កើនការយល់ដឹងស្តីពីរេដបូកទៅដល់ក្រុមខ្លួន សហគមន៍ និងជនជាតិដើមភាគតិចនៅមូលដ្ឋាន ជាជាងបង្កើនសមត្ថភាពសមាជិកក្រុមខ្លួន
- ក្រុមប្រឹក្សាយោបល់រេដបូកនឹងបង្ហាញឲ្យឃើញថា ក្រុមមានសមត្ថភាព មានការចូលរួម និងមានភាពជាម្ចាស់លើផែនការរបស់ខ្លួន ដូច្នេះដើម្បីបង្ហាញពីសមត្ថភាពនេះ កិច្ចប្រជុំបានស្នើសុំសមាជិកក្រុមប្រឹក្សាយោបល់ ដែលមានសមត្ថភាពដូចជា RECOFTC ត្រូវទទួលយកផែនការសកម្មភាពរបស់ក្រុមប្រឹក្សាយោបល់ ជាពិសេសសកម្មភាពសំខាន់ចាំបាច់ទៅអនុវត្តក្នុងនាមក្រុមប្រឹក្សាយោបល់រេដបូក។

ចុងបញ្ចប់សហប្រធាននៃអង្គប្រជុំ លោកបណ្ឌិត ឃនសារ៉េត និងលោកយាង ដូណាល់ បានថ្លែងអំណរគុណក្រុមប្រឹក្សាយោបល់រេដបូកទាំងអស់ដែលបានចូលរួមមតិយោបល់ ជួយឲ្យកិច្ចប្រជុំសម្រេចបានលទ្ធផលល្អ និងបានជូនពរឲ្យសមាជិកអង្គប្រជុំទាំងអស់សម្រេចការងារប្រកបដោយជោគជ័យ និងមានសេចក្តីសុខតរៀងទៅ។

ភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ ២០១៦

| សហប្រធាន | សហប្រធាន |
|---|---|
| លោកបណ្ឌិត ឃន សារ៉េត | លោក យាង ដូណាល់ |

## ឧបសម្ព័ន្ធ១៖ បញ្ជីឈ្មោះអ្នកចូលរួមកិច្ចប្រជុំលើកទី១៣របស់ក្រុមប្រឹក្សាយោបល់រេដបូកកម្ពុជា

ក្រុមការងាររេដបូកកម្ពុជា និងសមាជិកក្រុមប្រឹក្សាយោបល់

| ល.រ | ឈ្មោះ | តួនាទី | កំណត់សំគាល់ |
|---|---|---|---|
| ០១ | ឯកឧត្តម ជា សំអាង | ប្រធានក្រុមការងាររេដបូកកម្ពុជា | វត្តមាន |
| ០២ | លោកបណ្ឌិត ឃន សាវ៉េត | ប្រធានលេខាធិការដ្ឋានរេដបូកកម្ពុជា | វត្តមាន |
| ០៣ | លោក យាង ដូណាល់ | ប្រធានសមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ០៤ | លោក ធីត ឈន | អនុប្រធានសមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ០៥ | លោក ឈុន ឌីលុច | សមាជិកក្រុមបច្ចេកទេស | អវត្តមាន |
| ០៦ | លោក សៀក សុផាត | សមាជិកក្រុមប្រឹក្សាយោបល់ | អវត្តមាន |
| ០៧ | លោក គឹម សុបិន្ត | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ០៨ | លោក វ៉ៃ ប៊ុនរឿន | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ០៩ | លោក អាង ជាតិឡោម | សមាជិកក្រុមប្រឹក្សាយោបល់ | អវត្តមាន |
| ១០ | លោកស្រី ហ៊ូ កល្យាណ | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ១១ | លោក វ៉ា មឿន | សមាជិកក្រុមប្រឹក្សាយោបល់ | អវត្តមាន |
| ១២ | កញ្ញា តេង រិទ្ធីនី | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ១៣ | លោក សា ថ្លៃ | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ១៤ | លោក ម៉ៅ ង៉ា | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ១៥ | លោក ឡុង សូចែត | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ១៦ | លោក សៅ ជាង | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ១៧ | លោក ព្រំ ស៊ាវ៉ាត | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ១៨ | លោក គាន ហ៊ាន | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ១៩ | លោក វង្ស តារា | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ២០ | លោក ម៉ែន ប៉ាក់ | សមាជិកក្រុមប្រឹក្សាយោបល់ | វត្តមាន |
| ២១ | តំណាងវិស័យឯកជន | សមាជិកក្រុមប្រឹក្សាយោបល់ | អវត្តមាន |
| ២២ | លោក តុល សុជា | Alternate INGO-CG | វត្តមាន |
| ២៣ | លោក ញ៉ែម សុវណ្ណា | អ្នកចាត់ចែងកិច្ចប្រជុំ និងជាទីប្រឹក្សាគម្រោងមូលនិធិភាពជាដៃគូកាបូន ព្រៃឈើ | វត្តមាន |
| ២៤ | លោក លុន គឹមហ៊ី | អ្នកចាត់ចែងកិច្ចប្រជុំ និងជាអ្នកសម្របសម្រួលកម្មវិធីលេខាដ្ឋាន | វត្តមាន |
| ២៥ | លោកស្រី នួន ចិន្តា | អ្នកគាំទ្រដំណើរការកិច្ចប្រជុំ និងជាជំនួយការគម្រោង | វត្តមាន |
| ២៦ | លោក មន្នី វីរៈ | អ្នកគាំទ្រដំណើរការកិច្ចប្រជុំ និងជាមន្ត្រីរដ្ឋបាលគម្រោង FCPF | វត្តមាន |

| | | | |
|---|---|---|---|
| ២៧ | លោកស្រី គុជ សូលីដា | អ្នកគាំទ្រដំណើការកិច្ចប្រជុំ និងជាមន្ត្រីជំនួយការគម្រោង | វត្តមាន |
| ២៨ | កញ្ញា ហាប់ សុធារី | អ្នកគាំទ្រដំណើការកិច្ចប្រជុំ និងជាជំនួយការលេខាដ្ឋានរេដបូក | វត្តមាន |
| ២៩ | លោក តាំង ចិនម៉ៅ | អ្នកបើកបរគម្រោង FCPF, UNDP | វត្តមាន |
| ៣០ | លោក ហ៊ឹម សម្បត្តិ | អ្នកបើកបរគម្រោង FCPF, UNDP | វត្តមាន |
| **វត្តមាន ២៥ នាក់ អវត្តមាន ០៥នាក់** | | | |